# កោះត្រល់

លោក Charles Régismanset សរសេរថា : "ជនជាតិយួន ប្រើអំណាចគ្រប់សង្កត់គ្រប់ទិសទីកន្លែងផ្លាស់ប្តូរឈ្មោះទីក្រុង បង្ខំឲ្យខ្មែរនិយាយភាសាយួន ឲ្យស្លៀកពាក់ជាយួន ឲ្យយកទំនៀមទម្លាប់របស់យួន និងប្រថ្នាចង់ឲ្យដូរសាសនាខ្មែរទៀត" ។

លោក គ្រូពេទ្យ Pannetier និង លោកបណ្ឌិតខាងវិទ្យាលើមនុស្ស Verneau សរសេរថា យួនចូលមកឈ្លានពាន ប្រព្រឹត្តិអំពើឃោរឃៅ កំទេចស្នាដៃ និង អារ្យធម៌របស់ខ្មែរ (1) ។

ជាកស្តុតាងជាក់ស្តែងដែលបរទេសស្គាល់តែពាក្យ «ភូកុក»។ ឈ្មោះនេះមិនដឹងជាកើតនៅពេលណា ព្រោះថាអ្នកដែលរំលោភឈ្លានពានចូលមកលួចនៅមិនបានប្រាប់ទេ ហើយស្រែកបន្ទំបោកប្រាស ដាក់ឈ្មោះទីកន្លែងសារជាថ្មីឡើងវិញ ពីកោះត្រល់ ទៅ ភូកុក ។ កូនខ្មែរទាំងអស់គ្នា នៅតែហៅថាកោះត្រល់ ព្រោះជាកោះរបស់ខ្មែរ ។

## ក្នុងរជ្ជកាល ព្រះបាទ អង្គឌួង (១៨៤១ - ១៨៥៩)

នៅពេលដែលអ្នកបក់ផ្ចិតថ្វាយព្រះអង្គមានសញ្ជាតិជាសៀមគេងលក់ទៅ ព្រះអង្គក៏ចាត់អ្នកជំនិតទុកចិត្តរបស់ព្រះអង្គឲ្យប្រញាប់ប្រញាល់ រៀសរវៃទៅអញ្ជើញសម្តេចមិស្ស Monseigneur Jean Claude Miche មកសរសេរនៅក្នុងមុងជាមួយ ដើម្បីបកប្រែជាភាសាបារាំង តាមការហៅសូត្ររបស់ព្រះអង្គ ។

ខែវិច្ឆិកា ឆ្នាំ១៨៥៣ ព្រះបាទអង្គឌួង ទ្រង់ចាត់បញ្ជូនជាសម្ងាត់នូវបច្ចាជន ចៅពញាពេន និង ចៅពញាកុន (ឪពុកជាជនជាតិ ព័រទុយហ្គេ កាន់សាសនាកាតូលិក ម្តាយជាជនជាតិខ្មែរ) យកព្រះសារលិខិត : «ជានា ពីស្ថានភាពរបស់អ្នកផ្សាយសាសនា ពីមិត្តភាព និងគារវកេក្តីរបស់ព្រះអង្គ» អមនឹងជផ្លាយ "ភ្នុកដំរីធំ។៤, កុយរមាស២, ជ័រវត្ត ៧បាវស្មើនឹង៣០០គ.ក្រ, ស្កុស៥ហាប, ម្រេច៤ហាប" ទៅជូនលោកកុងស៊ុលបារាំង ប្រចាំកោះសិង្ហបូរី ដើម្បីទុកយកទៅថ្វាយ ព្រះចៅអធិរាជណាប៉ូឡេអុងទី៣ (2) ។

លោក Charles de Montigny សរសេរថា បេសកកម្មនេះបានសម្រេចជោគជ័យ ។

បន្ទាប់ពីបានទទួលព្រះសារលិខិត ព្រះចៅអធិរាជណាប៉ូឡេអុងទី៣ ក៏បញ្ជូនលោក Charles de Montigny ទទួលបន្ទុកធ្វើការចរចា ជាមួយនឹងព្រះបាទអង្គឌួង (3) ។

ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៨៥៦ ព្រះបាទអង្គឌួង អញ្ជើញលោកសង្ឃកាតូលិក Le Père Hestrest ដើម្បីប្រគល់ព្រះសារលិខិតជាលើកទី២ : « ស្នើបារាំងកុំឲ្យទទួលស្គាល់អធិបតេយ្យភាពអណ្ណាម និងការផ្តល់នូវទឹកដីណាមួយដែលទាក់ទងទៅនឹងទឹកដីរបស់ខ្មែរ » ទៅថ្វាយព្រះចៅអធិរាជណាប៉ូឡេអុងទី៣ អមទាំង "សំពត់ ៤គី និង ភ្លុកដំរី៤" ជាជផ្លាយ ទៀតផង (4) ។

ក្នុងឆ្នាំ ១៨៦៩ មានអ្នកប្រាជ្ញបារាំងសែសខាងភូមិសាស្ត្រមួយឈ្មោះ Malte-Brun បានគូរផែនទី (Carte du Royaume de Siam, de la Cochinchine française et du Royaume du Cambodge) ផាត់ពណ៌ខៀវនៅចំប្រទេសកម្ពុជានិងកោះត្រល់ ចេញផ្សាយ មុនពេលដែលប្រទេសបារាំងមានអធិបតេយ្យភាព នៅចុងបូព៌ាប្រទេស (Extrême-Orient) ពីឆ្នាំ១៨៨៥ ទៅដល់ឆ្នាំ១៩៤៥ មកម្ល៉េះ ។

ក្នុងឆ្នាំ ១៨៩១ លោក Charles Meyniard ក៏បានគូរផែនទីកោះត្រល់ផ្សាយជាសាធារណៈ ផ្សព្វផ្សាយជាទូទៅ និងឲ្យមហាអំណាច ស្គាល់ពីភូមិសាស្ត្រ និងយល់ច្បាស់ពីកោះត្រល់ ថាជាកោះរបស់ខ្មែរ ពិតប្រាកដ។

ក្នុងឆ្នាំ ១៨៥៤ នៅពេលដែលលោក Charles de Montigny អញ្ជើញមកដល់ទីក្រុងបាងកក ក្រឡាហោម រដ្ឋមន្ត្រីប្រទេសសៀមមកសុំជួបលោក ដើម្បីនឹងបង្ហាញផែនទីផ្ទៃសមុទ្រ ព្រមទាំងចង្អុលនៅលើកោះត្រល់ បិតនៅចំពីមុខខេត្តកំពត ដែលយួនដណ្ដើមយកទៅ (5) ។

## ក្នុងរជ្ជកាល ព្រះបាទ នរោត្តម (Ang Voddey) ១៨៦០ - ១៩០៤

លោកសង្ឃកាតូលិក (Bouilleveaux) សរសេរថា ក្រោយពីបានវាយកំទេចប្រទេសចម្ប៉ា នៅសល់តែ២ខេត្តប៉ុណ្ណោះ យួនក៏ចូលមកត្រួតត្រាកូសាំងស៊ីន សម្ងាប់លោកសង្ឃកាតូលិក ដោយប្រើវិធី កាត់ក, ច្របាច់ក. . . (6) ។

លោក Paulin Alexandre Vial និង លោក Albert Septans អនុនាវីទោទាំង២នាក់សរសេរថា កងទ័ពបារាំងជាមួយនឹងកងទ័ពអេស្ប៉ាញ៉ុល ចូលមកច្បាំងនឹងយួន ដើម្បីការពារសាសនាកាតូលិក។ ប្រជាពលរដ្ឋខ្មែរជាច្រើនបានចូលរួមយ៉ាងសកម្ម ដើម្បីដេញកងទ័ពអណ្ណាម ឲ្យចេញពីកូសាំងស៊ីន។ បារាំង និង អេស្ប៉ាញ៉ុល ច្បាំងឈ្នះយកបានខេត្តខ្មែរទាំងអស់នៅកូសាំងស៊ីន មកវិញ (7) - (8) ។

ពេលនោះ អនុនាវីទោបារាំង លោក Lespes អញ្ជើញមកជួបអ្នកតំណាងព្រះបាទនរោត្តម ដើម្បីរៀបចំមិត្តភាពឡើងវិញ រវាងបារាំង និងខ្មែរ តាមសំណូមពររបស់ព្រះបាទអង្គឌួង (9) ។

ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ព្រះបាទនរោត្តម ទ្រង់ឡាយព្រះហស្តលេខាជាមួយ លោក Doudart de Lagrée, Capitaine de frégate-premier représentant de protectorat français au Cambodge វរនាវីទោ តំណាងរាជការអាណាព្យាបាល បារាំងនៅប្រទេសកម្ពុជាស្តីពីសិទ្ធិសញ្ញា «អាណាព្យាបាល» (10) ។

ក្នុងឆ្នាំ ១៨៦៤ បារាំងដាក់នរោត្តម ឲ្យឡើងគ្រងរាជ្យ គឺផ្ដាច់ចេញស្រឡះពីយួន និងសៀម (11) ។

ថ្ងៃទី១៥ ខែមិនា ឆ្នាំ ១៨៧៤ បារាំងចុះសន្ធិសញ្ញា មិត្តភាពបារាំង ជាមួយយួន ដើម្បីពង្រីកអំណាចនៅចុងបូព៌ាប្រទេស Extrême-Orient ។ ក្នុងសិទ្ធិសញ្ញានោះ យួនសុំបារាំងឲ្យទ័ពចិន១ម៉ឺននាក់ចេញពី តុងកឹង។ ចិនមិនយល់ព្រមតាមការស្នើសុំរបស់បារាំង ព្រោះចិនទុកយួនជាសាសន៍ ហ្វាន់ (ពាក្យហ្វាន់ ចិនប្រែថារបង) សម្រាប់ការពារព្រំប្រទល់ដែនប្រទេសចិន ប៉ែកខាងត្បូង (12) ។

ចម្បាំងក៏កើតមានឡើងរវាងចិននិងបារាំងរហូតមកដល់ឆ្នាំ ១៨៨៥។ ចិនច្បាំងចាញ់បារាំង ក៏សុខចិត្តឲ្យកង ទ័ពចិនដើរចេញពីតុងកឹង ព្រមទាំងចុះហត្ថលេខាលើសិទ្ធសញ្ញា ស្តីពីការទំនាក់ទំនងពាណិជ្ជកម្មរវាងចិន និងបារាំង នៅទីក្រុង ទៀង ស៊ីន Tien Tsin ។

ចាប់ពីឆ្នាំ ១៨៨៥ មកបារាំងមានអធិបតេយ្យភាពនៅ ចុងបូព៌ាប្រទេស Extrême-Orient ដែលមានស្រុក តុងកឹង អណ្ណាម លាវ កម្ពុជា កូសាំងស៊ីន មានឈ្មោះថា ឥណ្ឌូចិនបារាំងសែស ។ អធិបតេយ្យភាពបារាំង បានបំផុស និងបញ្ជាក់ច្បាស់ពីសញ្ជាតិរបស់ប្រជាជននិមួយៗ ទៅតាមប្រទេសរៀងៗខ្លួន នៅក្នុងឥណ្ឌូចិនបារាំងសែស។ រដ្ឋបាល ឥណ្ឌូចិនបារាំងសែសរៀបចំបោះបង្គោលធ្វើកំណត់សំគាល់ តាមភូមិ តាមស្រុក តាមឃុំ និមួយៗ ដើម្បីងាយស្រួល ត្រួតត្រា និងទារយកពន្ធដារ ត្រឹមតែប៉ុណ្ណោះទេ (13) ។

## ក្នុងរជ្ជកាល ព្រះបាទ ស៊ីសុវត្ថិ ១៩០៤ - ១៩២៧

មកដល់ឆ្នាំ១៩០៧ បារាំងចុះលើសិទ្ធិសញ្ញាស្តីពី រឿងព្រំប្រទល់ខ្មែរសៀម ហើយសៀមព្រមប្រគល់ខេត្តខ្មែរ បាត់ដំបង, ស៊ីសុផុន, មង្គលបុរី ឲ្យមកឥណ្ឌូចិនបារាំងសែសវិញ។ ព្រំប្រទល់ដែនខ្មែរ-សៀម ក៏បានសម្រេច សន្ធត់ច្បាស់លាស់ត្រឹមត្រូវ និងបែងចែកច្បាស់នៅលើផ្ទៃសមុទ្រខ្មែរ ថែមទៀតផង (14) ។

## ក្នុងរជ្ជកាល ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ១៩២៧ -១៩៤១

ក្នុងឆ្នាំ១៩៣២ (នាឆ្នាំ ១៩៧៥ នៅទីក្រុងប៉ារីស ឧត្តមនាវី Pierre Robert បានប្រគល់មេដាយ ជាតំណាង នៃការស្រឡាញ់របស់គ្រួសារលោកមកលើគ្រួសារខ្ញុំ និងរំលឹកនូវអនុស្សាវរីយ៍ ពេលដែលលោកបានទួលមេដាយ កិត្តយសដោយផ្ទាល់ពីព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស នៅលើទឹកដីប្រទេសកម្ពុជាកាលពី ឆ្នាំ១៩៣២) (15) ។

ក្នុងឆ្នាំ១៩៣៩ លោកប្រេវីយេ អគ្គទេសាភិបាល ឥណ្ឌូចិនបារាំងសែស Brévié Gouverneur général de l'Indochine បានគូសខ្សែបន្ទាត់ដូចជាហុំព័ទ្ធកោះត្រល់ លើផ្ទៃសមុទ្រខ្មែរ គ្រាន់ត្រឹមតែជាការត្រួតត្រារដ្ឋបាលនិង ប៉ូលីស តែប៉ុណ្ណោះ ។

ក្នុងឆ្នាំជាមួយគ្នានេះ ជប៉ុនបានធ្វើមិត្តភាពជាមួយអាឡឺម៉ង់ ដើម្បីចង់ត្រួតត្រានៅអាស៊ី ប៉ាស៊ីហ្វិក ព្រោះ ហ៊ីត្លែរ ត្រួតត្រាគ្រប់គ្រងអឺរ៉ុបអស់ទាំងមូល ហើយ (16) ។

## ក្នុងរជ្ជកាល ព្រះបាទ នរោត្តម សីហនុ ១៩៤១ - ១៩៥៥

ក្នុងថ្ងៃទី៩ ខែ មិនា ឆ្នាំ១៩៤៥ បន្ទាប់ពីប្រទេសបារាំងចាញ់ ប្រទេសអាឡឺម៉ង់មក ពេលនោះហើយ ដែល បារាំងបាត់អស់អធិបតេយ្យភាពនៅ ឥណ្ឌូចិនបារាំងសែស (16) ។

ដូច្នេះ ទឹកដីសមុទ្ររបស់ខ្មែរឥតមានបាត់បង់ទេ គឺនៅតែដដែល។ ឯខ្សែបន្ទាត់លោក ប្រេវីយេ Brévié គូស ព័ទ្ធជុំវិញកោះត្រល់នោះ ក៏ត្រូវរលត់រលាយទៅតាមការបាត់បង់អធិបតេយ្យភាពបារាំងនៅឥណ្ឌូចិនដែរ ។

ត្រង់ចំណុចនេះហើយ ដែលធ្វើឲ្យខ្មែរទាំងអស់គ្នាមានការជឿងធ្ងល់ជាខ្លាំងថា បើបារាំងបាត់អស់អធិបតេយ្យភាពនៅឥណ្ឌូចិន ហេតុអ្វីបានជាតំណាងរាស្ត្របារាំង នាំគ្នាទៅបោះឆ្នោតនៅរដ្ឋសភាថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៤៩ ស្តីពីការផ្ទាប់រដ្ឋកូសាំងស៊ីន ទៅវៀតណាម ? ដែលមានសម្លេង ៣៥១ ប្រឆាំងនឹងសម្លេង ២០៩ ។

ការដែលផ្ទាប់រដ្ឋកូសាំងស៊ីន ទៅវៀតណាម កោះត្រល់មិននៅជាប់នឹងកូសាំងស៊ីនទេ ។ លោក Général Aumeran ជាតំណាងរាស្ត្រ អាល់ស៊េរ (កូឡូនី) Député d'Alger ប្រកែកថា ការដែលផ្ទាប់រដ្ឋកូសាំងស៊ីនទៅវៀតណាមនោះ គឺធ្វើទៅមិនកើតទេ ក៏ពីព្រោះតែស្រុកវៀតណាមនោះមិនទាន់កើតផង។ លោកមានប្រសាសន៍នេះច្បាស់ពិតប្រាកដ ព្រោះលោកសំអាងទៅលើរដ្ឋមួយដែល Hô Chi Minh ជាមេទ័ពវៀតមិញបានបង្កើតរដ្ឋឯករាជ្យសាធារណរដ្ឋវៀតណាម នៅពេលដែលជប៉ុនចុះហត្ថលេខា ជាមួយសម្ពន្ធមិត្ត (អាមេរិកាំង, អង់គ្លេស, បារាំង, ចិនជាតិនិយម) ពីការចុះចាញ់ ក្នុងសង្គ្រាមលោកលើទី២ នា ថ្ងៃទី២ ខែកញ្ញា ឆ្នាំ ១៩៤៥ ។

ការបង្កើតរដ្ឋនេះ គឺធ្វើឡើងខុសពីគំនិត «សហភាពបារាំង» Union Française ទាំងស្រុង ថែមទាំងបណ្តេញប្រជាពលរដ្ឋ និងទាហានបារាំងឲ្យចេញពីហាណូយ ចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៦ (17) ។

ក្នុងឆ្នាំ១៩៤៩ នេះទៀត បារាំងបានយកកងទ័ពចិនជាតិនិយម ៣៥ ០០០ នាក់មកទុកនៅ កោះត្រល់ ដោយសារតែលោក ម៉ៅសេង ទុង ចិនកុម្មុយនិសឈ្នះចម្បាំងនិង ចិនជាតិនិយម។ ការដែលយកកងទ័ពចិនជាតិនិយមមកទុកនៅកោះត្រល់នោះ បានបញ្ជាក់ថាបារាំងមិនបានភ្លេចនូវសំណូមពរដែលព្រះបាទអង្គឌួង បានសុំទៅព្រះចៅអធិរាជណាប៉ូឡេអុងទី៣ ទេ បានសេចក្តីថា អធិបតេយ្យភាពខ្មែរនៅតែមាន នៅលើកោះត្រល់ដដែល (18) ។

ក្នុងថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៣ បារាំងប្រគល់ ឯករាជ្យឲ្យមកព្រះរាជាណាចក្រកម្ពុជា (19) ។

## ក្នុងសម័យ សង្គមរាស្ត្រនិយម ១៩៥៥ - ១៩៦៩

ក្នុងឆ្នាំ ១៩៥៥ សម្តេចព្រះនរោត្តមសីហនុដាក់រាជ្យ បន្ទាប់មកព្រះអង្គក៏បានបង្កើតសង្គមរាស្ត្រនិយម ។

ក្នុងឆ្នាំ១៩៥៦ សម្តេចព្រះនរោត្តមសីហនុ សុំបារាំងឲ្យសង់កំពង់ផែនៅកំពង់សោម ដោយសារយួនបិតផ្លូវទឹកទន្លេមេគង្គមិនឲ្យកុប៉ាល់ជំនួញចូលមកភ្នំពេញ។ ព្រះបាទអង្គឌួង យល់ច្បាស់ពីប្រយោជន៍បន្ទាន់នូវការសាងសង់កំពង់ផែនៅកំពត ទើបតែដល់១០ឆ្នាំ ក្រោយមកបារាំងបានសង់កំពង់ផែនោឯ កំពង់សោម វិញ ក្នុង ឆ្នាំ១៩៥៨ (20) ។

## ក្នុងរជ្ជកាល ព្រះបាទ នរោត្តម សុរាម្រិត ១៩៥៥ - ១៩៦០

ក្នុងឆ្នាំ១៩៥៧ នាថ្ងៃទី៧ ខែមិថុនា សម្តេចព្រះនរោត្តម សីហនុ ក្នុងឋានៈជានាយករដ្ឋមន្ត្រី បានបញ្ជាឲ្យរាជរដ្ឋាភិបាលចាត់វិធានការរក្សាការពារកោះក្រចកសេះ។

ក្នុងឆ្នាំ១៩៥៧ នៅព្រះបរមរាជវាំង ព្រះបាទ នរោត្តម សុរាម្រិត បានចេញព្រះរាជក្រឹត្យ ស្តីពីការ កំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រនៃប្រទេសកម្ពុជា និងបញ្ជាក់ច្បាស់ថាប្រទេសកម្ពុជារក្សាសិទ្ធិកោះត្រល់ជាដែនប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (យោងតាមមាត្រា៦ នៃក្រិត) លេខ 662-NS du 30 Décembre 1957 (21) ។

*ក្នុងឆ្នាំ១៩៥៨ ប្រទេសកម្ពុជាបានចូលរួមជំនុំនៅក្នុងសន្និសិទ្ធលើកទី១ ជាមួយនឹង ៨៦ប្រទេស ព្រមទាំង ២០ តំណាងអង្គការនានានៃអង្គការសហប្រជាជាតិនៅស្វីហ្សែរស្តីពី «សិទ្ធិសមុទ្រ» ដឹកនាំដោយលោក ប្លែក ឆាត* (22) ។

## *ក្នុងជំនាន់ សម្តេចសីហនុ ប្រមុខរដ្ឋនៃប្រទេសកម្ពុជា ១៩៦០ - ១៩៧០*

*ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៦០ ឯក ឧត្តម តាសឺន សាន បញ្ជាក់នៅក្នុងក្រសួងការបរទេសចុះលេខ* 322-DGP/X*ថា អធិបតេយ្យភាពខ្មែរ នៅតែមានទៅលើកោះត្រល់ដដែល។*

*ក្នុងឆ្នាំ១៩៦០ សម្តេចសីហនុ បានអញ្ជើញលោក ជូ អេង ឡាយ និង លោក ចិន យី មកក្រុងកែប ដើម្បីមើលកោះរបស់ខ្មែរ ។*

*ប្រធានាធិបតីនៃប្រទេសចិនប្រជាមានិតលោក ជូ អេង ឡាយ មានប្រសាសន៍ថា : " ការទាមទារបស់ប្រទេសវៀតណាមខាងត្បូងមិនត្រឹមត្រូវទេ ពីព្រោះកោះទាំងអស់នេះជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជាជាដរាប។*

*...នៅពេលណាដែលវៀតណាមចូលមករាតត្បាតប្រទេសកម្ពុជា អំពើនេះត្រូវតែផ្តន្ទាទោស ប្រជាជនចិនទាំង ៦៥០លាននាក់ នឹងនៅខាងប្រទេសកម្ពុជា "។*

*ទល់មុខក្រុងកែប មានកោះទន្សាយ កោះត្បាល់ កោះពោធិ កោះអង្រ្កង កោះសេះ (កោះដែលមើលឃើញនោះ គឺកោះទន្សាយ)* (23) ។

*ក្នុងឆ្នាំ១៩៦៣ លោក តាន់ គិម ហួន វិស្វករខាងក្សេត្រសាស្ត្រ គង្គា និងរុក្ខា បានបោះពុម្ពសៀវភៅក្រោមចំណងជើង «ភូមិសាស្ត្រប្រទេសកម្ពុជា» ដែលលោកសរសេរបញ្ជាក់ថាកោះត្រល់ ជាកោះរបស់ខ្មែរពិតប្រាកដ ។*

*ក្នុងឆ្នាំ១៩៦៩ «កោះត្រល់» ចុះនៅក្នុងបញ្ជីកាក្នុងចំណោម ៦៤កោះ ផ្សាយចេញពីទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងរ៉ែ លេខ២៦១ ។*

## *ក្នុងជំនាន់ សាធារណរដ្ឋខ្មែរ ដឹកនាំដោយលោក សេនាប្រមុខ លន់ នល់ ១៩៧០ - ១៩៧៥*

*ដោយសារតែមានការស្រាវជ្រាវរកប្រេងកាត នៅ* Golfe du Siam *ប្រទេសខ្មែរ និងប្រទេសយួនខាងត្បូង បានមកជួបជុំគ្នានៅភ្នំពេញ ស្តីពីបញ្ហាសមុទ្រ បន្ទាប់មកក៏បានជួបជុំគ្នាម្តងទៀតនៅ ឯ ព្រៃនគរ ដឹកនាំដោយ ឯកឧត្តម សៀន ប៉េងសែ រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម ។*

*ក្នុងឆ្នាំ១៩៧២ រដ្ឋាភិបាល លោកលន់ នល់ បានបញ្ជាក់ម្តងទៀតពីអធិបតេយ្យភាពរបស់ប្រទេសកម្ពុជានៅលើខ្ពង់រាបបាតសមុទ្រខ្មែរ ហើយប្រាប់ទៅគ្រប់ក្រុមហ៊ុនឥន្ធនៈទាំងអស់ថា គ្មានច្បាប់ណាមួយអាចមកធ្វើអាជីវកម្មនៅលើតំបន់នេះ ដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលខ្មែរទេ* (24) ។

## ក្នុងសម័យ សាធារណរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការសហប្រជាជាតិ ទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ និងមានសិទ្ធិកាន់កាប់អាសនៈកម្ពុជាប្រចាំអង្គការសហប្រជាជាតិ។ ខ្មែរក្រហមបានបំផ្លិចបំផ្លាញសេដ្ឋកិច្ច ធ្វើបាបនិងកាប់សម្លាប់ប្រជាជន ធ្វើឲ្យប្រទេសចុះទន់ខ្សោយ បំផ្លិចបំផ្លាញរចនាសម្ព័ន្ធដឹកនាំបក្សរបស់ខ្លួនផ្ទាល់ឲ្យមានការបែកបាក់ក្នុងជួរថ្នាក់អ្នកដឹកនាំ។ ជាឱកាសពិសេសមួយដ៏ល្អបំផុតហុចឲ្យវៀតណាមចូលមកយ៉ាងងាយស្រួលមិនចាំបាច់ខិតខំឬខាតបាត់បង់អ្វីទាំងអស់ មកឈ្លានពានប្រទេសកម្ពុជាសម្រេចតាមគោលបំណងដោយជោគជ័យ ថែមទាំងមានឈ្មោះថា ជាអ្នកមានគុណមករំដោះខ្មែរឲ្យរួចផុតពីការប្រល័យពូជសាសន៍ របស់ខ្មែរក្រហមទៀតផង ។

ក្នុងឆ្នាំ១៩៧៥ នាវាជំនួញអាមេរិកាំង Mayaguez បើកចូលក្នុងផ្ទៃសមុទ្រខ្មែរ កងទ័ពខ្មែរក្រហមបានឃាត់នាវានោះទុកនៅកោះតាំង។ ៤ថ្ងៃក្រោយមក កងទ័ពអាមេរិកាំងបានមករំដោះនាវា យកទៅវិញ ក្នុងខែឧសភា ឆ្នាំ១៩៧៥ (25) ។

ក្នុងឆ្នាំ២០០១ លោកអគ្គបញ្ជាការរដ្ឋបាលនៅសមុទ្រប៉ាស៊ីហ្វិក Dennis Blair Commandant en Chef de l'Administration des Etats-Unis dans le Pacifique ចាប់ដៃទាហានខ្មែរពេលដែលលោកអញ្ជើញមកកោះតាំង ចម្ងាយ ១៤៩ ម៉ែល៍ ពីទីក្រុងភ្នំពេញ (26) ។

លោក François Joyaux និង លោក Couteau-Bégarie បានសរសេរថា ខ្មែរក្រហម បានលើកទ័ពទៅយកកោះត្រល់នៅក្នុង ឆ្នាំ១៩៧៥ តែត្រូវបរាជ័យនៅចំពោះមុខកងទ័ពយួនដែលមានច្រើនលើសជាងទ័ពខ្មែរក្រហម ។

ក្នុងខែមិថុនា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជជែកពីរឿងកោះ នៅហាណូយស្តីពី ផ្ទៃសមុទ្រខ្មែរ ទ័ពយួនក៏បានចុះចេញពីកោះ Poulo wai (27) - (28) ។

## ក្នុងសម័យ សាធារណរដ្ឋ ប្រជាមានិតកម្ពុជា ១៩៧៩-- ១៩៩០

ខ្មែរក្រហម ដែលតែងតែតាំងខ្លួនជាអ្នកការពារប្រទេស ពីការរំលោភរបស់វៀតណាមនោះ គឺជាអ្នកបានចូលរួមចំណែកយ៉ាងធំមួយក្នុងការជួយវៀតណាមឲ្យបានសម្រេចនូវសេចក្តីប៉ុនប៉ងប្រាថ្នាដែលកប់ទុកជាយូរឆ្នាំមកហើយ ពីការចង់ចូលមកកំទេចឲ្យដូចប្រទេសចម្ប៉ា ហើយយកមកកាន់កាប់ត្រួតត្រា ទុកធ្វើជាប្រទេសរបស់ខ្លួន ។

ក្នុងឆ្នាំ១៩៨៤ អនុវត្តន៍ផែនការណ៍ ក៥ ជញ្ជាំងឬស្សី ជារបបប្រល័យពូជសាសន៍ខ្មែរ ចាប់តាំងពីអាយុ១៨ ឆ្នាំទៅ៣៥ឆ្នាំ។ អ្នកដែលបានរត់រួចនិយាយថា ពេលទៅជិះឡាន ពេលត្រឡប់មកវិញជិះចាន បានសេចក្តីថា ជាតុមួយកញ្ចប់ យកមកឲ្យគ្រួសារ (29)

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបណ្តេញ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចេញពីភ្នំពេញ តែត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់រដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ ស្របច្បាប់របស់កម្ពុជាដដែល គ្រាន់តែផ្លាស់ទីតាំងពីភ្នំពេញ មកនៅព្រំដែនខ្មែរ-ថៃ ប៉ុណ្ណោះ ។

ចំណែកឯរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ ប្រទេសអាមេរិក ប្រទេសចិន និងប្រទេសថៃ ប្រានចោលទាំងស្រុងមិនទទួលស្គាល់ រដ្ឋាភិបាលនេះទេ ព្រោះជារដ្ឋាភិបាលបង្កើតឡើងដោយវៀតណាម ។

ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានចេញឡើងជាផ្លូវការ ឋិតនៅក្រោមអាណានិគម វៀតណាម ។

ថ្ងៃទី១២ ខែមករា ឆ្នាំ ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្ហាញរូបរៀងជាផ្លូវការ ។

## សន្ធិសញ្ញា និងកិច្ចព្រមព្រៀងព្រំដែនខុសច្បាប់ ឯកសារ របស់ឯកឧត្តម ស៊ាន ប៉េងសែ

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពី សន្តិភាព មិត្តភាព និងសហប្រត្តិបត្តិការ មានរយៈ២៥ឆ្នាំ នឹងត្រូវបន្តជាស្វ័យប្រវត្តិ១០ឆ្នាំម្តងៗ។ ក្នុងឆ្នាំ២០១៤ នេះត្រូវចប់ ១០ឆ្នាំ លើកទី១ បើគណបក្សប្រជាជននៅតែបន្ត គឺធ្វើរហូតដល់ ទៅឆ្នាំ២០២៤ ។

សន្ធិសញ្ញានេះបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ជាមួយនឹងលោកប្រធានក្រុមប្រឹក្សាប្រជាមានិតកម្ពុជា ហេង សំរិន ៦ អាទិត្យ ក្រោយពីកងទ័ពយួនបានចូលមកកាន់កាប់ប្រទេសកម្ពុជា ។

សន្ធិសញ្ញានេះ ជាសន្ធិសញ្ញាចម្បងគេ ដែលគាត់តែងឡើងសម្រាប់លុបចោលនូវការទទួលស្គាល់របស់ប្រទេសយួនលើបូរណភាពទឹកដីខ្មែរ បន្តបន្ទាប់គ្នាចាប់តាំងពីឆ្នាំ១៩៥៤ នៅពេលសន្និបាតអន្តរជាតិនៅក្រុងហ្សឺណែវ ពីរឿងឥណ្ឌូចិន ម្តងទៀតនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦២ ជាមួយប្រទេសដទៃទៀតខ្លះដូចជាប្រទេសបារាំង លើកទី៣នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៦៧ ដែលផ្តួចផ្តើមឡើងដោយសម្តេចព្រះនរោត្តមសីហនុ ។

សន្ធិសញ្ញានេះធ្វើឲ្យកងទ័ពវៀតណាមប្រមាណ១៥ម៉ឺននាក់ និងស៊ីវិល ចូលមកនៅលើទឹកដីកម្ពុជា។ វៀតណាមបានដាក់ អ្នកជំនាញការនៅតាមគ្រប់មន្ទីរ ក្រសួង នៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨២ ដែលបានចុះហត្ថលេខាដោយលោក ង្វៀង គីថាច់ ជាមួយនឹងលោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេសលើសន្ធិសញ្ញា ស្តីពី តំបន់ទឹកប្រវត្តិសាស្ត្រ។ កិច្ចព្រមព្រៀងនេះបានប្រគល់កោះត្រល់ និងកោះក្រចកសេះ ឲ្យទៅយួន ផ្តាច់ជាស្ថាពរ ។

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ ដែលបានចុះហត្ថលេខាដោយលោក ង្វៀង គីថាច់ ជាមួយនឹងលោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេសលើសិទ្ធិសញ្ញា ស្តីពី គោលការណ៍ដើម្បីដំណោះស្រាយព្រំដែន និងកិច្ចព្រមព្រៀង ស្តីពី លក្ខន្តិកៈព្រំដែន រវាង ស.ស.វ. និង ស.ប.ក. ។

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ ដែលបានចុះហត្ថលេខាដោយលោក ង្វៀង គីថាច់ ជាមួយនឹងលោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេសលើសិទ្ធិសញ្ញា ដែលធ្វើឡើងបន្ទាប់ពីមានការគ្រោងទុកនៅលើសន្ធិសញ្ញាចុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ ស្តីពី គោលកាណ៍ ដើម្បីដំណោះស្រាយព្រំដែន ព្រមទាំងបន្ទាប់ពីមានការសម្រេចរបស់គណៈកម្មាធិការចម្រុះខ្មែរ-យួន នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨៤ និងថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៨៤ ។

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩ ចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមនៅលើសន្ធិសញ្ញាកំណត់ព្រំដែន រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាមនៅទីក្រុងហាណូយប្រទេសវៀតណាម (៣០) ។

## រដ្ឋាភិបាលចម្រុះត្រីភាគី

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី សម្តេច នរោត្តម សីហនុ ខៀវ សំផន និង ឯក ឧត្តមសឹន សាន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី : " រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ " ដែលមានសម្តេចព្រះ នរោត្តម សីហនុ តំណាង ហ៊្វុនស៊ិនប៉ិច FUNCINPEC ជាប្រមុខរដ្ឋ, ឯក ឧត្តមសឹន សាន តំណាងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងជានាយករដ្ឋមន្ត្រី, លោក ខៀវ សំផន តំណាងខ្មែរក្រហម ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស។ អង្គការសហប្រជាជាតិ ទទួលស្គាល់ រដ្ឋាភិបាលត្រីភាគី ជារដ្ឋាភិបាលស្របច្បាប់ និងជាអ្នកកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិទៀតផង ។

ថ្ងៃទី២១ ខែមិនា ឆ្នាំ១៩៨១ នៅព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង សម្តេចសីហនុ ទ្រង់បានបង្កើត «រណសិរ្សបង្រួបបង្រួមជាតិ ដើម្បីកម្ពុជា ឯករាជ្យ អព្យាក្រឹត សន្តិភាព និង សហប្រតិបត្តិការ» (ហ៊្វុនស៊ិនប៉ិច LE FRONT UNI NATIONAL POUR UN CAMBODGE INDÉPENDANT, NEUTRE, PACIFIQUE ET COOPÉRATION « FUNCINPEC ») ក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ជាប្រធាន, លោក ញឹក ជូឡុងជាអនុប្រធានទី១ និង លោក អ៊ិន តាំ ជាអនុប្រធានទី២ ។

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៩ " សមាគមខ្មែរទូរទៅនៅបរទេស " បានទទួលស្គាល់ពីរដ្ឋាភិបាលបារាំងដែលមាន ឯកឧត្តមសឹន សាន ជាប្រធាន ។

ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩ នៅជំរំសុខសាន្ត (ព្រំប្រទល់ខ្មែរ- ថៃ) វរជន និងយុទ្ធជន ព្រមទាំងចលនាតស៊ូទាំងអស់បានទៅជួបជុំគ្នានៅតំបន់ភ្នំបន្ទាត់ដើម្បីប្រកាសបើកជាផ្លូវការពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ក្រោមការដឹកនាំរបស់លោកប្រធាន សឺន សាន ។

រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ គឺជារណសិរ្សនៃអ្នកតស៊ូជាតិនិយម ទាំងនៅតាមជាយដែនខ្មែរ-ថៃ ទាំងនៅក្នុងប្រទេស ព្រមទាំងនៅឯនាយសមុទ្រ ដើម្បីសង្គ្រោះ បំរើ ការពារ ប្រជាពលរដ្ឋ :

- រំដោះប្រទេសកម្ពុជា ពីការកាន់កាប់របស់កងទ័ពវៀតណាមឈ្លានពាន
- ទប់ទល់ មិនឲ្យរបបប្រល័យពូជសាសន៍ ប៉ុល ពត វិលត្រឡប់មកវិញ
- កសាងជាថ្មីឡើងវិញនូវកម្ពុជា ឯករាជ្យ សេរី មានអធិបតេយ្យភាព និងអស់អំពើពុករលួយ ។ (31)

## ការបង្កើត ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ Conseil National Suprême ១៩៩០

ឈ្មោះរដ្ឋ និងគណបក្សទាំងអស់ ព្រមទាំងសន្ធិសញ្ញានិងកិច្ចព្រមព្រៀងពីមុនមក ត្រូវលុបចោលទុកជាអសារបង់ (32) ។

### កិច្ចព្រមព្រៀង ក្រុងប៉ារីស ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១

មុននឹងចុះហត្ថលេខាពីកិច្ចព្រមព្រៀង ប្រធានាធិបតីបារាំង លោក François Mitterrand បានរំលឹកថា អធិបតេយ្យភាពមិនអាចដកហូតចេញពីប្រជាពលរដ្ឋទេ។ ចាប់ពីពេលនេះទៅ ប្រជាពលរដ្ឋខ្មែរ នឹងរកឃើញវាសនាសំរេចគោលនយោបាយរបស់ខ្លួនផ្ទាល់ទៅអនាគត និងមិនទទួលស្គាល់នូវការឈឺចាប់ ។

សន្និសិទ្ធ អន្តរជាតិនៅទីក្រុងប៉ារីស ស្តីពីប្រទេសកម្ពុជា បានប្រព្រឹត្តឡើងក្រោមសហអធិបតេយ្យភាព នៃប្រទេសបារាំង និងប្រទេសឥណ្ឌូនេស៊ីដែលមានតំណាងរៀងៗខ្លួន ដោយរដ្ឋមន្ត្រីការបរទេស រ៉ូឡង់ ឌុយម៉ាស និងអាលី អាឡាតាស់។ ភាគីជម្លោះកម្ពុជាទាំងបួន និង១៨ប្រទេសទៀត ក៏បានចូលរួមក្នុងសន្និសិទ្ធនេះដែរ។

កិច្ចព្រមព្រៀងដើម្បីដំណោះស្រាយនយោបាយរួមនៃជម្លោះនៅកម្ពុជា ក៏ត្រូវបានធ្វើជាសច្ចាប័នដ៏មហោឡារិក និងជាសេចក្តីសង្ឃឹមនៃពិភពលោក។ ប្រទេសកម្ពុជា សង្ឃឹមជាចុងក្រោយថា អាចនឹងធ្វើអោយខ្លួនឯងនឹងស្គាល់វិបុលភាព ក្នុងការគោរពសិទ្ធិមនុស្សសេរីភាព ប្រជាធិបតេយ្យ និងបូរណភាពជាតិ (33) ។

### ថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ បោះឆ្នោត (34)

### ខែកញ្ញា ឆ្នាំ១៩៩៣ បង្កើតរដ្ឋធម្មនុញ្ញថ្មីមួយ (35)

## កោះត្រល់ជាកោះរបស់ខ្មែរពិតប្រាកដ

ដោយសំអាងទៅលើច្បាប់ប្រវត្តិសាស្ត្រ ច្បាប់អន្តរជាតិស្តីពីច្បាប់សមុទ្រ និងតាមលក្ខណៈច្បាប់ធម្មជាតិ-ភូមិសាស្ត្រ ដែលបានកំណត់និងបញ្ជាក់ច្បាស់ណាស់ថា កោះណាដែលដុះនៅជិតដែនដីគោករបស់ប្រទេសណាមួយ គឺកោះនោះជាសម្បត្តិរបស់ប្រទេសនោះ។ ថ្ងៃក្រោយកោះនេះនឹងដុះដីមកជាប់នៅនឹងដីខេត្តកំពតក្នុងប្រទេសខ្មែរ ។

ជាពិសេសទៅទៀតនោះកោះត្រល់មានចម្ងាយ ១៥គីឡូម៉ែត្រ ពីខេត្តកំពត និង៤៥គីឡូម៉ែត្រ ពីតំបន់ ហាទៀង ឈ្មោះវៀតណាមបច្ចុប្បន្ន។ តំបន់នេះមានឈ្មោះថា ក្រមួនស-ពាម ឋិតនៅលើដីកម្ពុជាក្រោម (កូសាំងស៊ីន) ជាដីរបស់ខ្មែរ ដែលខ្មែរយើងមិនទទួលស្គាល់ថាជាដីយួន តាំងពី ឆ្នាំ១៩៤៩មក។ រហូតមកដល់សព្វថ្ងៃនេះ ខ្មែរនៅតែទាមទារពីយួនជានិច្ចជាកាលមិនដែលភ្លេច នូវកេរ្តិ៍ដីខ្មែរនេះ ដើម្បីយកទៅប្រគល់ឲ្យកូនចៅខ្មែរវិញ ។

ក្នុងឆ្នាំ១៩៥៨ សន្និសិទ្ធអង្គការសហប្រជាជាតិ នៅទីក្រុង ស្ហ៊ីណែវ ចាប់ពីខែកុម្ភៈ ដល់ខែមេសា ស្តីពី «សិទ្ធិសមុទ្រ»។ អង្គការសហប្រជាជាតិបានចេញលិខិតជាផ្លូវការនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៦០ លេខ១៣៩ ពីផ្នែកកិច្ចការច្បាប់នៃអង្គការ ។

ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៨ សម្តេចព្រះនរោត្តម សីហនុ បានឡាយព្រះហស្ថលេខាលេខ ៣៧៨/៦៨CE ស្តីពីអនុសញ្ញា«ខ្ពង់រាបបាតសមុទ្រ» ។

ថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៨៦ សម្តេចព្រះនរោត្តម សីហនុ ជាប្រធានរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានបដិសេធ និងផ្តន្ទាទោស នូវកិច្ចព្រមព្រៀង និងសន្ធិសញ្ញា ទាំងអស់ដែលធ្វើឡើងរវាងកម្ពុជានិងវៀតណាម ។

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៨៦ ក្នុងលិខិតថ្លែងការណ៍ផ្ញើទៅអង្គការសហប្រជាជាតិ ប្រទេសសិង្ហបូរីបានបញ្ជាក់ថា កិច្ចព្រមព្រៀងរវាងខ្មែរ និងវៀតណាមស្តីពី«តំបន់ទឹកប្រវត្តិសាស្ត្រ» មិនស្របនឹងច្បាប់អន្តរជាតិទេ។ ដោយហេតុថា អ្នកដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ធ្វើឡើងដោយយួនបង្ខំ ពេលដែលយួនចូលមកឈ្លានពាន ហើយ ក៏មិនមែនជាអ្នកតំណាងប្រទេស ឬតំណាងប្រជាពលរដ្ឋខ្មែរទេ គឺរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យតែមួយគត់ ដែល បានទទួលស្គាល់ពីសំណាក់ប្រទេសជាច្រើនរបស់អង្គការសហប្រជាជាតិ (36) ។

ក្នុងលិខិតថ្លែងការណ៍ផ្ញើទៅអង្គការសហប្រជាជាតិ ឯកឧត្តម សឺន សាន មិនទទួលស្គាល់ ច្រានចោលសន្ធិសញ្ញា ស្តីពី *គោលការណ៍ ដើម្បីដំណោះស្រាយព្រំដែន* ដែល ស.ស.វ. និង ស.ស.ក. បានចុះហត្ថលេខា នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ (៣៧) ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីស :

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ :

បានសេចក្តីថា កិច្ចព្រមព្រៀងណាដែលធ្វើឡើងនៅក្រោមការត្រួតត្រារបស់បរទេស ក្រោមការគៀបសង្កត់ពី កងទ័ពបរទេស ក្រោមការគំរាមកំហែងដោយកងប្រដាប់អាវុធ ព្រោះពេលនោះ យួននៅគ្រប់គ្រងប្រទេសកម្ពុជាទាំងមូល គឺជាការរំលោភខុសច្បាប់ គឺខុសពីឆន្ទៈ របស់រាស្ត្រខ្មែរ ដែលរស់នៅក្នុងប្រទេសខ្មែរ ។

បើយើងលើកយកប្រវត្តិសាស្ត្រពិភពលោកមកលាតត្រដាង យើងនឹងឃើញថា នាពេលដែលប្រទេសបារាំងមានអធិបតេយ្យភាព ក្នុងពេលដែលកងទ័ពណាស៊ីចាញ់ចំបាំងក្នុង ថ្ងៃទី៨ ខែឧសភា ឆ្នាំ ១៩៤៥ លោកឧត្តមសេនីយដឺហ្គោល ជាប្រធានអ្នកប្រយុទ្ធរបស់ប្រទេសបារាំង និងជាប្រធានគណៈកម្មាធិការជាតិ បានចេញដីកាមួយមាន១៣មាត្រា ធ្វើនៅទីក្រុងឡុងដ៍ ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៤៣។ ដីកានេះ បញ្ជាឲ្យលុបគ្រប់សន្ធិសញ្ញា និងច្បាប់ដែលរដ្ឋវិស៊ី (L'Etat de Vichy) ព្រមព្រៀងជាមួយនឹងកងទ័ពណាស៊ី ហើយនឹងឲ្យបោះបង់ចោលទាំងអស់ ។

លោក Jean Brethe de la Gressaye សាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ខេត្តបរ័ដោ (Bordeaux) ក៏បានបញ្ជាក់ពីការលុបបំបាត់គ្រប់កិច្ចព្រមព្រៀង និងសន្ធិសញ្ញាណាដែលបានធ្វើជាមួយនឹងកងទ័ពណាស៊ីដែរ (38) ។

បន្ទាប់ពីចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ក្រោមសហប្រធាននៃប្រទេសបារាំង នាយករដ្ឋមន្ត្រីកម្ពុជាបច្ចុប្បន្ន មិនបានលុបចោល នូវសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលបានចុះហត្ថលេខាជាមួយ និងសាធារណរដ្ឋ សង្គមនិយមវៀតណាមទេ។

ក្នុងឆ្នាំ ១៩៩៣ ថ្ងៃទី១៩ ខែកក្កដា សម្តេចព្រះ នរោត្តម សីហនុ ប្រធានឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានផ្ញើព្រះសារលិខិត ទៅថ្វាយសម្តេចក្រុមលួង នរោត្តម រណឫទ្ធិ និង ឯក ឧត្តម ហ៊ុន សែនក្នុងពេលដែលអញ្ជើញ

ទៅធ្វើទស្សកិច្ចនៅប្រទេសវៀតណាម ត្រូវប្រាប់ឲ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមឲ្យដាក់បង្គោលព្រំប្រទល់ ខ្មែរ-ឡើងវិញ ដែលគេទទួលស្គាល់ជាផ្លូវការនាឆ្នាំ ១៩៦០ និង១៩៧០។ កន្ទែងខ្លះបង្គោលព្រំប្រទល់ ខិតចូលមកជ្រៅក្នុងដីប្រទេសកម្ពុជានាឆ្នាំ១៩៨០ បង្គោលទាំងអស់នោះត្រូវតែបំផ្លាញចោល ។

ចំណែកខាងផ្ទៃក្រឡាដែនទឹកសមុទ្រ មិនត្រូវឲ្យខុស ផ្សេងដំទៃ ពីកិច្ចព្រមព្រៀង ទទួលស្គាល់អំពីប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម និង រណៈសិរ្សជាតិរំដោះប្រទេសវៀតណាមខាងត្បូង នៅឆ្នាំ១៩៦០ ។

មិត្តភាពរវាងប្រទេស និង រវាងប្រជាពលរដ្ឋយើងទាំងពីរ មានភាពជាក់លាក់ពិត និងរឹងមាំស្ថិតនៅលើការគោរព ព្រំប្រទល់ដែន ផ្ទៃដី និងផ្ទៃទឹក... (39) ។

ក្នុងឆ្នាំ២០០៩ ព្រះបាទសម្តេច នរោត្តម សីហនុទាមទារទឹកដី និងកោះរបស់ខ្មែរនៅចំពោះ មុខលោក Jean-Marie Cambacérès (40) ។



លោកបណ្ឌិត កែម ឡី អ្នកស្រាវជ្រាវសង្គម និងសេដ្ឋកិច្ច ឯករាជ្យបញ្ចេញទស្សនៈថា តាមផ្លូវច្បាប់ បើរដ្ឋាភិបាលមានឆន្ទៈ ចង់ទាមទារកោះត្រល់ពីវៀត ណាមវិញ មិនទាន់ហួសពេលទេ។ ការទាមទារកោះ ត្រល់មកជាសម្បត្តិខ្មែរវិញ អាចធ្វើឡើងតាមរយៈទ្វេ ភាគី ឬតាមលក្ខណៈអន្តរជាតិ ដោយត្រូវពិនិត្យសើរើ កិច្ចព្រមព្រៀង ឬសន្ធិសញ្ញារវាងកម្ពុជានិងវៀតណាម កន្លងមក។ ករណីកោះត្រល់ បើរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នមិនហ៊ានចេញមុខទាមទារមកជាសម្បត្តិខ្មែរទេ រដ្ឋាភិបាលជាប់ឆ្នោតថ្មី ឬក៏ក្មេងៗជំនាន់ក្រោយក៏អាច ទាមទារតាមផ្លូវច្បាប់យកកោះត្រល់ពីវៀតណាមបានមកវិញដែរ ។

**សូមគោរព និងរំលឹកដល់វិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី ដែលដក់ជាប់នៅក្នុងបេះដូងកូនខ្មែរជានិច្ច ។**

ចាយ សិរីវុឌ្ឍន៍

ប៉ារីស, ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៦